SWIS-H
STATEWIDE INFANT SCREENING - HEARING

# ហេតុអ្វីបានជាទារករបស់ខ្ញុំត្រូវបានគេបញ្ជូនដោយភ្លាមៗសម្រាប់ការវាយតម្លៃរោគវិនិច្ឆ័យលើការស្តាប់សូរសម្លេង?



ទារករបស់អ្នកនឹងបានទទួលការឆែកពិនិត្យមើលសុខភាព ជាបន្តបន្ទាប់នៅក្នុងរវាងពេល២-៣សប្តាហ៍ដំបូង បន្ទាប់ពីបានកើតមក។ ការឆែកពិនិត្យមើលមួយក្នុងចំណោមការឆែកពិនិត្យទាំងនេះ គឺដើម្បីរកមើលការបាត់បង់សោតវិញ្ញាណ (ការស្តាប់មិនសូវឮ)។

ការពិនិត្យមើលសោតវិញ្ញាណនឹងមានផ្តល់តាមលទ្ធភាពអាចធ្វើទៅបាន បន្ទាប់ពីបានកើតមក។ ទោះជាយ៉ាងណាក្តី ការពិនិត្យមើលនេះមិនសមរម្យសម្រាប់ទារកមួយចំនួន ដោយហេតុថាការពិនិត្យមើលប្រហែលជាមិនពិតប្រាកដទេនៅក្នុងករណីទាំងនេះ។ ជាជំនួសវិញនោះ ទារកទាំងនេះនឹងត្រូវគេបញ្ជូនដោយភ្លាមៗសម្រាប់ការវាយតម្លៃរោគវិនិច្ឆ័យសោតវិញ្ញាណ ដោយគ្រូពេទ្យសោតវិញ្ញាណដែលជាអ្នកឯកទេសសោតវិញ្ញាណ។

## ហេតុអ្វីបានជាទារករបស់ខ្ញុំត្រូវគេបញ្ជូនដោយភ្លាមៗសម្រាប់ការវាយតម្លៃរោគវិនិច្ឆ័យសោតវិញ្ញាណ?

មូលហេតុមួយចំនួនចំពោះការបញ្ជូនដោយភ្លាមៗ រួមមានៈ

- ពុំមានរន្ធត្រចៀក
- ត្រចៀកពុំទាន់កើតចេញរូបរាងពេញលក្ខណៈ
- បាក់តេរី ឬវ៉ាយរ៉ុសរលាកស្រោមខួរ (បញ្ជាក់ច្បាស់ ឬសង្ស័យ)
- ឆែបមាត់ / ប្រេះក្រអូមមាត់
- រោគ Down Syndrome

ទារកណាដែលចំណាយពេលច្រើននៅក្នុងមន្ទីរមើលថៃយ៉ាងខ្លាំងក្លា ក៏អាចត្រូវអ្នកសម្របសម្រួលកម្មវិធី WISH បញ្ជូនដោយភ្លាមៗដែរ សម្រាប់ការវាយតម្លៃរោគវិនិច្ឆ័យសោតវិញ្ញាណ បន្ទាប់ពីបានពិគ្រោះជាមួយគ្រូពេទ្យកុមារ ទោះបីជាទារកទាំងនោះបានជាប់ការពិនិត្យមើលសោតវិញ្ញាណក្តី។

មានទារកប្រហែល១នាក់ ទៅ២នាក់ ក្នុងចំណោមទារក១០០០នាក់ដែលកើតមក នឹងមានការបាត់បង់សោតវិញ្ញាណដ៏ធ្ងន់ធ្ងរ។

ជាការសំខាន់ដែលអ្នកត្រូវស្វែងយល់ឲ្យបានដឹងយ៉ាងឆាប់ តាមលទ្ធភាពអាចធ្វើទៅបានថាតើទារករបស់អ្នកស្តាប់ឮល្អយ៉ាងណាដែរ ដើម្បីឲ្យអ្នក ហើយនិងទារករបស់អ្នកអាចទទួលបានឱវាទ និងការផ្គត់ផ្គង់ត្រឹមត្រូវ។

ប្រសិនបើអ្នករស់នៅឆ្ងាយជាង១០០គីឡូម៉ែត្រ ពីមន្ទីរពេទ្យដែលគេបានបញ្ជូនអ្នក សូមសាកសួរបុគ្គលដែលផ្តល់កូនសៀវភៅព័ត៌មាននេះមកអ្នក ដើម្បីទទួលព័ត៌មានអំពីគ្រោងការណ៍ជំនួយលើការធ្វើដំណើរ SWIS-H។

សម្រាប់ព័ត៌មានអំពីការវាយតម្លៃរោគវិនិច្ឆ័យសោតវិញ្ញាណ សូមសាកសួរបុគ្គលដែលផ្តល់សន្លឹកព័ត៌មាននេះមកអ្នក ´ហេតុអ្វីបានជាកូនរបស់ខ្ញុំត្រូវការឲ្យមានការវាយតម្លៃរោគវិនិច្ឆ័យសោតវិញ្ញាណ?´

### សម្រាប់ព័ត៌មានបន្ថែម សូមបើកចូលវ៉ិបសាយខាងក្រោមនេះ៖

http://www.health.nsw.gov.au/kids-families

### ការទាក់ទងក្នុងតំបន់ / ព័ត៌មានលំអិតអំពីការណាត់ជួប

សម្រាប់ឱវាទផ្នែកសុខភាព សូមទាក់ទង *healthdirect Australia*
http://www.healthdirect.gov.au/
**1800 022 222**

NSW GOVERNMENT | Health

© NSW Health September 2016 SHPN (NKF)150287